# ទស្សនៈស្ដីពីជីវិតនិងការរស់នៅរបស់ព្រះពុទ្ធសមណគោតម

*ដោយៈ លោក* **ឈុន ផាវ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*ថ្ងៃ១៥កើត ខែពិសាខ[1] គឺជាថ្ងៃបុណ្យពិសាខបូជា ប្រចាំឆ្នាំដ៏សំខាន់បំផុតសម្រាប់ពុទ្ធសាសនិកនៅទូទាំងសកលលោក ដើម្បីរំលឹកដល់ថ្ងៃប្រសូត្រ ថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វាននៃព្រះពុទ្ធសមណគោតម។ ព្រះអង្គជាបុគ្គលដែលមានគុណូបការៈធំធេងចំពោះមនុស្សជាតិ ដោយបានជួយជីវិតមនុស្សសត្វឱ្យរស់នៅប្រកបដោយសេចក្តីសុខចាកទុក្ខតាមរយៈព្រះធម៌។ ព្រះអង្គមាននាមដើមសិទ្ធត្ថ ឬ សិទ្ធាថ៌ គឺជាបុត្រានៃមហាក្សត្រត្រកូលសាក្យ នៃប្រទេសឥណ្ឌាបុរាណ។ បិតារបស់ព្រះអង្គខិតខំប្រឹងរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីរៀបចំឱ្យព្រះអង្គស្នងរាជសម្បត្តិ ប៉ុន្តែព្រះ អង្គមិនទទួលយកជីវិតរស់នៅបែបនោះឡើយ។ ព្រះអង្គបានបោះបង់សម្បត្តិលោកិយ ចាកចេញពីរាជវាំង ឃ្លាតចាកប្រពន្ធកូន ស្រីស្នំ និងទ្រព្យទាំងឡាយ ដោយទៅបួសជាសមណក្នុងគោលបំណងស្វែងរកការពិតនៃជីវិត។ ព្រះអង្គបាន ប្រព្រឹត្តនូវតបធម៌ ធ្វើនូវទុក្ករកិរិយាតាមប្រពៃណីអ្នកបួសសម័យនោះ អស់រយៈពេល៦ព្រះវស្សា។ ក្រោយពីបោះបង់ចោលវិធីខុសឆ្គងនេះ ព្រះអង្គបានប្រព្រឹត្តិមជ្ឈិមាបដិប្បទា (វិធីកណ្តាល) ដោយខ្លួនឯងវិញ។ ទីបំផុត ព្រះអង្គបានរកឃើញទ្រឹស្តី ចតុរារិយសច្ចៈ ដែលជាការពិតប្រសើរជាងសម្មតិសច្ចៈ។ តើ ព្រះធម៌ដែលព្រះអង្គបានត្រាសដឹង បានបង្ហាញអ្វីខ្លះអំពីទស្សនៈស្តីពី «ជីវិត និង ការរស់នៅ» ?*

## ២. អត្ថន័យនៃពាក្យ ជីវិត និង ការរស់នៅ

*ពាក្យជីវិត និង ការរស់នៅ ក្នុងអត្ថបទនេះមានអត្ថន័យ ផ្សេងគ្នា។ ជីវិត គឺសំដៅ លើជាតិ, កំណើត, ការតាំងមានឡើង។ រីឯ ការរស់នៅ សំដៅការបន្តស្ថិតនៅមានជីវិតក្នុងអត្ថិភាពណាមួយ, ការនៅមានអាយុ, ការមិនទាន់ស្លាប់, ការមិនទាន់រលត់ខន្ធ, ការមិនទាន់ធ្លាយខន្ធ, ការមិនទាន់ធ្លាយសង្ខារ។*

*មានទស្សនៈយល់ផ្សេងគ្នា អំពីសារជាតុនិងការកើតមាននៃជីវិត។ ចំពោះព្រះពុទ្ធ ព្រះអង្គយល់ថា ជីវិត (ឬបដិសន្ធិ) ជាការផ្សំនៃមហាភូត*

*[1] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិក៏បានប្រកាស ទទួលស្គាល់វិសាខបូជាជាពិធីបុណ្យអន្តរជាតិ។*

រូប៤ គឺទឹកដីភ្លើងខ្យល់ ដែលបង្កើតនូវខន្ធ៥ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ។ ហើយការស្លាប់ (ឬចុតិ) ជាការរលត់នៃខន្ធ៥ ទៅកាន់ទឹកដីភ្លើង ខ្យល់វិញ។ ទឹកដីភ្លើងខ្យល់គឺជាធាតុអវិជ្ជា ជាធាតុមិនដឹងថាខ្លួនជាអ្វី, ជាធាតុល្ងង់, ជាភាវមោហៈ។

ព្រះពុទ្ធបង្ហាញថា ក្នុងរយៈពេលរស់នៅសត្វលោកដែលកើតពីអវិជ្ជាត្រូវអវិជ្ជារួបរឹតធ្ងឹតភ័ន្តច្រឡំយល់ខុសថាជាត្រូវ ទៅតាមសម្មតិសច្ចៈ ឬការពិតតាមការសន្មតិ ឬតាមកត្តាអត្តនោម័តិ) គឺមានតែបញ្ញា ឬវិជ្ជា)ទេដែលអាចរំដោះពីការភ័ន្តច្រឡំទៅរកការយល់ត្រឹមត្រូវ តាមសច្ចភាពបរានុម័ត ឬសច្ចភាពសត្យានុម័តបាន។

ចំពោះការកើតស្លាប់នៃជីវិត ព្រះពុទ្ធថាជារឿងហួសនិស្ស័យក្នុងការគិត (អចិន្តេយ្យ) សម្រាប់មនុស្សសាមញ្ញ (បុថុជ្ជន)។ អំពីការស្លាប់កើតនៃជីវិត គឺមានអ្នកយល់ខុសចាកគន្លងធម៌ (មនុស្សមិច្ឆាទិដ្ឋិ) ជាច្រើនដូចជា៖ ១.សស្សតទិដ្ឋិ យល់ថាទៀងទាត់បិតបេរ គឺជាតិនេះធ្លាប់កើតជាសត្វ ទៅលោកខាងមុខក៏កើតជាសត្វទៀតមិនប្រែប្រួល។ ២.ឧច្ឆេទទិដ្ឋិ យល់ថាដាច់សូន្យសោះ គឺស្លាប់ហើយមិនកើតទៀត។ ៣.សកាយទិដ្ឋិការយល់ថា ស្លាប់ហើយកើតទៀត។ នេះជាមិច្ឆាទិដ្ឋិ ព្រោះសម្គាល់ថា នាមរូបជាអត្តា គឺជឿថាចិត្តកាយ ជារបស់ខ្លួន ឬប្រកាន់ថាបញ្ចក្ខន្ធជារបស់ខ្លួន។ មិច្ឆាទិដ្ឋិនេះឯងជាឫសគល់នៃបាបអកុសលគ្រប់ជំពូក។ ពុទ្ធិសាមញ្ញរបស់មនុស្ស មិនអាចគិតពិចារណា ហួសពីដែននៃឧប្បនិស័យរបស់ខ្លួនឡើយ។ ព្រះពុទ្ធបញ្ជាក់ថា អចិន្តេយ្យ៤យ៉ាង គឺ៖ ១.ពុទ្ធវិសយោ ពុទ្ធវិស័យ ការប្រព្រឹត្តទៅនៃព្រះពុទ្ធ។ ២.ឈាន វិសយោ ឈានវិស័យ ការប្រព្រឹត្តទៅនៃឈាន។ ៣.កម្មវិបាកោ ផលនៃកម្ម។ ៤. លោកចិន្តា ការគិតអំពីលោក[2]។ ចតុរារិយសច្ចៈ ដែលព្រះពុទ្ធសមណៈគោតមបានរកឃើញ បានបញ្ជាក់យ៉ាងច្បាស់អំពីទស្សនៈស្តីអំពី ជីវិត និងការរស់នៅរបស់មនុស្ស សត្វ និងទេវតា ប៉ុន្តែ បុថុជ្ជន (ដែលមានពុទ្ធិសាមញ្ញ) មិនអាចយល់ដឹងបានឡើយ គឺមានតែព្រះអរហន្តដែលបានត្រាស់ដឹង (ដែលមានពុទ្ធិទស្សនវិជ្ជា) ទេ ដែលអាចយល់ដឹងបាន។

## ៣.ដំណើរស្វែងរកការពិតរបស់ព្រះសិទ្ធត្ថ

មុនការរកឃើញ ទ្រឹស្តីចតុរារិយសច្ចៈ ព្រះសិទ្ធាថ៌ពោធិសត្វបានរៀនពីឧត្តកតាបសរាមបុត្រ សម្រេចបានឈាន[3]សមាបត្តិ ទី៨ គឺការពិចារ

---

[2] សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត អបណ្ណកវគ្គទី ៣ អចិន្តេយ្យសូត្រទី៧ បិដកលេខ៤២ ទំព័រ១៩៧

[3] ឈានទាំងនេះមានលំដាប់អង្គដូចជា៖ ១.វិតក្កៈ សេចក្តីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២.វិចារៈ សេចក្តីរំពឹង ពិចារណាអារម្មណ៍ ដែលកំពុងភាវនា; ៣.បីតិ សេចក្តីឆ្អែតចិត្ត; ៤.សុខៈ សេចក្តីសប្បាយក្នុងចិត្ត; ៥.ឯកគ្គតា ដំណើរមូលចិត្តស្ទុងទៅក្នុងអារម្មណ៍តែមួយ ( អង្គទាំង ៥ នេះ សំដៅចំពោះតែអារម្មណ៍ដែលស្ងប់ស្ងាត់ចាកកាមគុណ); ៦.លះវិតក្កៈ និងវិចារៈ ចេញនៅសល់តែ បីតិ និងសុខៈ ដែលកើតជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ជា ៣ នឹង ឯកគ្គតា; ៧.លះបីតិ ចេញនៅសល់តែសុខៈនិងឯកគ្គតា; ៨.លះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា២ នឹង ឯកគ្គតា។

ណាគ្មានអារម្មណ៍អ្វីសោះឡើយ។ ឧទ្ទកតាបស មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការចេះចាំដ៏អស្ចារ្យនេះ។ ឧទ្ទកតាបសបានពោលទៅកាន់ព្រះសិទ្ធត្ថថា៖ «បពិត្រព្រះសមណៈ! ព្រះអង្គមានការលូតលាស់យ៉ាងសម្បើមក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ហើយបានសម្រេចដល់កំរិតខ្ពស់បំផុតនូវចំណេះដែលអាត្មាមាន។ អាត្មាចង់ឱ្យព្រះអង្គស្នាក់នៅទីនេះគ្រាន់បានជាគ្នា ដោយអាត្មាគិតថាព្រះអង្គអាចជំនួសអាត្មាក្នុងឋានៈជាអ្នកគ្រប់គ្រង គណៈនេះបន្ទាប់ពីពេលអាត្មាស្លាប់ទៅ »។ ចំណែកព្រះសមណសិទ្ធត្ថបានយល់ដឹងយ៉ាងច្បាស់ថា ភាវៈនៃការមានសញ្ញាខ័ន្ធនិងការគ្មាន សញ្ញាខ័ន្ធមិនមែនជាកូនសោរសំរាប់រំដោះឱ្យផុតអំពីការកើតនិងការស្លាប់បានឡើយ។ ហេតុដូច្នោះហើយបានជាព្រះអង្គសម្រេចព្រះហឫទ័យថា ព្រះអង្គត្រូវតែធ្វើដំណើរបន្តទៅមុខ ទៀត។ ព្រះអង្គប្រកែកមិនព្រមទទួលសំណូមពរឧទ្ទកតាបសនេះទេ ដូចកាលដែលព្រះអង្គធ្លាប់ បានប្រកែកនឹងអាឡារតាបសពីមុននោះដែរ។ បន្ទាប់មក ព្រះសមណសិទ្ធត្ថក៏លើកព្រះហស្តថ្វាយបង្គំលា និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះឧទ្ទកតាបសរាមបុត្រនិងបព្វជិតជាសំឡាញ់ប្អូនរយរូបទៀត រួចហើយក៏និមន្តចៀសចេញទៅ។

ព្រះសិទ្ធត្ថនិមន្តឆ្ពោះទៅទិសខាងលិច ឆ្លងកាត់តាមវាលកក់ ដងអូរនិងស្ទឹង នេរញ្ជរា។ ព្រះអង្គយាងដល់ភូមិមួយឈ្មោះ ទងសិរី នៅក្នុងដែនមគធៈ។ ព្រះសមណសិទ្ធត្ថទ្រង់សម្រេចព្រះទ័យ ស្វែងរក មោក្ខធម៌ ដោយខ្លួនឯងនៅទីនេះ ដរាបណាព្រះអង្គបានរកឃើញពន្លឺត្រាស់ដឹង។ ព្រះអង្គជ្រើសរើសបានគុហាមួយដែលល្មមព្រះអង្គអាចគង់ធ្វើសមាធិបានយូរ។ ពេលព្រះសិទ្ធត្ថគង់ធ្វើសមាធិម្តងៗព្រះអង្គបានរំលឹកឡើងវិញនូវការអនុវត្តន៍ទាំងឡាយដែលព្រះ អង្គធ្លាប់បានប្រតិបត្តិក្នុងរវាង៥ឆ្នាំកន្លងមកហើយ។ ពេលនេះ ព្រះអង្គប្តូរព្រះចិន្តាមកសញ្ជឹងគិតដោយប្រុងប្រយ័ត្ន លើរូបកាយរបស់ព្រះអង្គផ្ទាល់វិញម្តង។ ព្រះអង្គសម្រេចធ្វើ អត្តកិលមកម្ម (ធ្វើទុក្ខទោសខ្លួនឯង) ដើម្បីដោះ ទុក្ខវេទនាឱ្យចេញផុតអំពីខ្លួន។ ព្រះអង្គធ្វើទុក្ករកិរិយា ក្នុងរបៀបបីគឺ៖ ១.យកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន (ក្រអូមខាងលើ) ២. ទប់ខ្យល់ដង្ហើមចេញចូល និង ៣. បន្ថយអាហារជាលំដាប់ រហូតនៅប៉ុនគ្រាប់សណ្តែក។ នៅក្នុងរាត្រីដ៏ងងឹតសូន្យសុងមួយ ព្រះសិទ្ធត្ថបានយាងចូលទៅក្នុងព្រៃស្ងាត់ដែលសម្បូណ៌ទៅដោយសត្វព្រៃយ៉ាងកាចសាហាវ។ ព្រះអង្គទ្រង់គង់នៅក្រោមដើមពោធិ៍ជ្រៃមួយ ហើយក៏ចាប់ផ្តើមតាំងនូវ តាបសធម៌ យ៉ាងខ្លាំង។ ពេលសត្វប្រើសមួយដើរមកជិត បន្លឺសម្លេងធ្វើក្រិកៗ ការភ័យខ្លាចរបស់ព្រះអង្គក៏បានបញ្ជាក់ឱ្យដឹងថាវាគ្រាន់តែជា បិសាចដែលមកបន្លាច និង

---

បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ចួបប្រទះសេចក្តីសុខសប្បាយធម្មតា ឆ្ងាញ់ពីសាជាងរសជាតិអ្វីៗ ទាំងអស់ ។

យាយីដល់ព្រះជន្មព្រះអង្គ ប៉ុន្តែព្រះអង្គគ្មានការភ្ញាក់ផ្អើលឬកំរើកសោះឡើយ។ ពេលសត្វក្ងោកកាច់បំបាក់មែកឈើងាប់តូចៗចុះមក ការភ័យរបស់ព្រះអង្គបានប្រាប់ព្រះអង្គឱ្យដឹងថាវាគ្រាន់តែជាពស់ថ្លាន់ដែលធ្លាក់ចុះអំពីដើមឈើប៉ុណ្ណោះ ព្រះអង្គក៏នៅតែមិនកំរើកព្រះកាយដដែល។ សូម្បីតែស្រមោចអង្ក្រងខាំឬសន្សើមធ្លាក់ទទឹកជោគព្រះអង្គកាយយ៉ាងត្រជាក់ក៏ព្រះអង្គនៅតែមិនកំរើកដែរ។ ពេលមួយនោះ ព្រះអង្គទ្រាំទប់ខ្យល់ដង្ហើមយ៉ាងយូរទាល់តែលាន់សូរពោទ៍ដូចរន្ទះ ឬក៏ហាក់ដូចជាមានដុំភ្លើងដ៏ក្តៅបុកមាំងក្នុងព្រះកាណ៌ និងព្រះសិររបស់ព្រះអង្គ។ ទ្រង់មានព្រះអារម្មណ៍បីដូច ជាគេយកពូថៅមកពុះចំព្រះកេសបំបែកជាពីរចំណែកដាច់ចេញពីគ្នា។ ជួនកាលព្រះអង្គ ចាប់អារម្មណ៍ហាក់ដូចជាគេគាបច្របាច់ព្រះកេសដោយបន្ទះដែកដ៏មាំៗ រីឯក្រពះរបស់ ព្រះអង្គក៏ត្រូវគេគាត់ចំហរធ្លុងដូចជាសត្វពពែដែលត្រូវគេកាប់ចិញ្ច្រាំ។ ព្រះអង្គព្យាយាម ហើយព្យាយាមទៀតដើម្បីឱ្យបានឈ្នះលើសេចក្តីភ័យខ្លាចទាំងអស់ ដែលមាននៅក្នុង រូបកាយរបស់ព្រះអង្គ។ ព្រះអង្គជឿថារូបកាយព្រះអង្គនឹងឥតមានរុំព័ទ្ធដោយសេចក្តីភ័យ ខ្លាចទៀតទេ។ គំនិតព្រះអង្គអាចកាច់បំបាក់នូវច្រវាក់នៃសេចក្តីឈឺចាប់បាន។ ដោយការអនុវត្តន៍ដ៏តឹងរឹងនេះព្រះអង្គអាចកំណត់នូវសេចក្តីក្លាហាននិងវិន័យរបស់ព្រះអង្គបាន និងខាងរូបកាយក៏ព្រះអង្គអាចអត់ទ្រាំនូវការឈឺចាប់ដ៏សែនទារុណបានដែរ។ ព្រះអង្គក៏ធ្វើ វិចារណៈថា៖ «គ្មានតាបសឥសីណាមួយ ក្នុងអតីតកាលក្តី ក្នុងបច្ចុប្បន្នកាលក្តី និងក្នុងអនាគតកាលក្តី ដែលបានប្រតិបត្តិ ឬកំពុងប្រតិបត្តិ ឬនឹងប្រតិបត្តិដោយភាពតឹងរឹងបំផុតជាងរូបអាត្មា អញនេះទេ។» តែដួងហឫទ័យព្រះអង្គនៅតែគ្មានសន្តិភាពសោះ។ ព្រះអង្គបានខំហាត់ពត់នូវតបកម្មរបៀបនេះអស់រយៈពេល៦ខែមកហើយក៏នៅពុំទាន់បានសម្រេចគោលបំណងដែរ។ ក្នុងរយៈពេលបីខែដំបូងព្រះអង្គព្យាយាមធ្វើធម៌តែមួយអង្គ ឯងនៅលើភ្នំ។ ក្នុងកំឡុងខែទី៤ ព្រះអង្គបានទទួលភិក្ខុ៥អង្គទៀតជាគូរួមទាំងកោណ្ឌញ្ញ ព្រាហ្មណ៍ធ្លាប់ទាយលក្ខណៈព្រះអង្គកាលពីព្រះអង្គទើបប្រសូត។ កូនព្រាហ្មណ៍ទាំងអស់ បបួលគ្នាចេញទៅបួសតាមបណ្តាំបិតារបស់ខ្លួន បន្ទាប់ពីបានដឹងថា ព្រះអង្គម្ចាស់សិទ្ធត្ថ យាងចេញបាត់មក។ ភិក្ខុទាំង៥អង្គនោះគឺ៖ កោណ្ឌញ្ញ១ វប្បៈ១ កទ្ទិយ១ អស្សជិ១ និង មហានាម១។ ជារៀងរាល់ថ្ងៃ ព្រះសិទ្ធត្ថនិងភិក្ខុទាំង៥អង្គ តែងត្រាច់ទៅបិណ្ឌបាតក្នុងទីក្រុង។ ចង្ហាន់ដែលបានមកពីការបិណ្ឌបាតនោះ ត្រូវបែងចែកជា៦ចំណែកស្មើៗគ្នា។ឃើញថាគ្មានភិក្ខុអង្គណាមួយបានចង្ហាន់ច្រើនលើសពីពំនូតក្នុងមួយថ្ងៃៗឡើយ។ ថ្ងៃខែចេះតែកន្លងផុតទៅ ភិក្ខុទាំង៦អង្គចុះស្គមស្គាំងយ៉ាងខ្លាំង មកពីឆាន់មិនគ្រប់ គ្រាន់។ ព្រះសិទ្ធត្ថនិងបញ្ចវគ្គិយភិក្ខុសម្រេចនិមន្តចាកចេញពីភ្នំទងសិរីនេះឆ្ពោះទៅទិស ខាងកើតទៅកាន់ភូមិ

មួយឈ្មោះ ឧរុវេលនិគម (សព្វថ្ងៃហៅ ឧរេស) នៅប្របក្រុង គយា (សព្វថ្ងៃហៅ គយាដដែល) ដែលស្ថិតនៅខាងស្តាំមាត់ស្ទឹងនេរញ្ជរា (សព្វថ្ងៃហៅ ស្ទឹង ផល្គុ)។ នៅពេលនេះការធ្វើទុក្ករកិរិយារបស់ព្រះសិទ្ធត្ថក៏ចាប់ផ្តើមឱ្យឃើញសញ្ញា ឡើងនិងសូម្បីតែកល្យាណមិត្តភិក្ខុទាំង៥រូបក៏ដូច្នោះដែរ។ ព្រះសិទ្ធត្ថនិងភិក្ខុទាំង៥រូប តែងតែឈប់ចុះស្រង់ទឹកនិងចែកចង្ហាន់គ្នា ឆាន់នៅមាត់ស្ទឹងនេរញ្ជរា។ ជួនពេលខ្លះព្រះ សិទ្ធត្ថនិងភិក្ខុទាំង៥រូប ឆាន់តែផ្លែត្របែក ស្ងួតដែលជ្រុះនៅលើដី។ ក្នុងរយៈពេល៦ខែ នៃការធ្វើ មហាបធានទុក្ករកិរិយា (កិរិយានៃការព្យាយាមធំ) នេះព្រះសិទ្ធត្ថមានព្រះកាយ ចុះស្គមស្គាំង មើលឃើញតែឆ្អឹងជំនីររវាមនិងស្បែកស្ងាំ ងទន់ខ្សោយ ហួសប្រមាណ។ នៅ ពាក់កណ្តាលផ្លូវ នាពេលដែលព្រះអង្គយាងមកពីស្រង់ទឹកនិងបោកស្បង់ចីវរនាស្ទឹងនេរញ្ជរាវិញ ព្រះអង្គទ្រង់ខ្សោះអស់ព្រះកាយពលយ៉ាងខ្លាំង រហូតដល់ដេកសន្លប់ស្តូកស្តឹងនៅលើប្រឹថពី។

ថ្ងៃមួយ ក្នុងពេលព្រះអង្គគង់ធ្វើសមាធិ ព្រះសិទ្ធត្ថយល់ដឹងដោយក្តីរន្ធត់នូវផ្លូវខុស នៃការធ្វើអត្តកិលមកម្មនេះ។ ព្រះអង្គទ្រង់សន្និដ្ឋានថា៖ «ផ្លូវនេះមិនមែនជាផ្លូវ នៃកិរិយា ត្រាស់ដឹងឡើយ។» ព្រះអង្គទ្រង់បានយល់ឃើញច្បាស់ទៀតថា៖ "រូបកាយនិងចិត្តកើតឡើងនៅក្នុងបុព្វហេតុតែមួយ ដែលមិនអាចបែងចែកដាច់អំពី គ្នាបាន។ បើមានសន្តិភាព(សេចក្តីស្ងប់) កើតឡើងនៅក្នុងផ្លូវកាយសន្តិភាពក៏អាចកើត មាននៅក្នុងផ្លូវចិត្តដែរ និងបើមានការគំរាមកំហែងខាងផ្លូវកាយក៏មានការគំរាមកំហែងខាង ផ្លូវចិត្តដែរ។" ក្នុងថ្ងៃដដែលនោះ ព្រះសមណ សិទ្ធត្ថបានសម្រេចព្រះទ័យបោះបង់ចោលនូវការធ្វើទុក្ករកិរិយាដល់ខ្លួនឯង។ ព្រះអង្គនិមន្តទៅកាន់ត្រើយម្ខាងនៃស្ទឹងដើម្បីប្រតិបត្តិធម៌តាម ធម្មតានៅទីនោះវិញ។ ព្រះពោធិសត្វក៏ពិចារណារកឃើញហេតុផល។ ១. អ្នកមានកាយនិងចិត្តមិនចេញចាកកាម មិនអាចនឹងត្រាស់ដឹងបានទេ ប្រៀបដូចជាឈើស្រស់ជុះ(ត្រាំ)ក្នុងទឹក យកទៅកួតគ្នាមិនឆេះជាភ្លើងទេ។ ២. អ្នកមានកាយចេញចាកកាមហើយ ប៉ុន្តែចិត្តមិនទាន់ចេញ មិនបានត្រាស់ដឹងទេ ប្រៀបដូចជាឈើស្រស់ជុះ (ឬនៅ)លើគោក យកទៅកួតមិនឆេះជាភ្លើងទេ។ ៣. អ្នកមានកាយនិងចិត្តចេញចាកកាមហើយ អាចនឹងត្រាស់ដឹងបានដោយប្រាកដ ប្រៀបដូចជាឈើស្ងួតនៅលើគោគ យកទៅកួតគ្នាក៏អាចឆេះជាភ្លើងបាន។ ដោយការបានយល់ច្បាស់នូវឧបមាទាំងបីខនេះ ព្រះសិទ្ធត្ថក៏ចាប់សម្រួលទាំងខាង ផ្លូវកាយទាំងខាងផ្លូវចិត្តហើយក៏ចាប់ផ្តើមសោយអាហារដូចធម្មតាវិញ។ ព្រះអង្គទ្រង់លះ បង់ការប្រតិបត្តិនូវអត្តកិលមថានុយោគ ហើយក៏ត្រឡប់មកប្រតិបត្តិតាមផ្លូវ មជ្ឈិមាបដិបទា ដែលជាផ្លូវកណ្តាល ដូចជាសម្លេងខ្សែពិណដែលតឹងល្មមដ៏ពីរោះនោះវិញ។ បន្ទាប់ពីពេលនោះមកជួនកាលនាង សុជាតាយកចង្ហាន់មកប្រគេន ជួនកាលព្រះអង្គ

និមន្តចេញទៅបិណ្ឌបាតផ្ទាល់ព្រះអង្គតាមលំដាប់ភូមិអ្នកស្រុក។ ព្រះសមណៈសិទ្ធត្ថចាប់បន្តធ្វើសមាធិទាំងយប់ទាំងថ្ងៃ នៅក្រោមម្លប់ដើមពោធិព្រឹក្សពិចារណាលើ កាយ ចិត្ត សញ្ញាក្ខ័ន្ធ និងអារម្មណ៍ ទាំងអស់ដែលមាននៅក្នុងគំនិតរបស់ព្រះអង្គ។ ក្នុងពេលជាមួយគ្នានេះ បញ្ចវគ្គិយភិក្ខុមិនបានឋិតនៅក្នុងព្យាករណ៍របស់ខ្លួនទៀត ឡើយ។ ភិក្ខុទាំង៥រូបមានការទាស់ចិត្តយ៉ាងខ្លាំង កាលបានឃើញព្រះសិទ្ធត្ថញញឹមរាក់ ទាក់និងទទួលយកទឹកដោះគោអំពីដៃក្មេងស្រី ព្រមទាំងឃើញព្រះអង្គឆាន់ចង្ហាន់ដែលបាន មកអំពីភូមិអ្នកស្រុកទៀតផង។ កោណ្ឌញ្ញភិក្ខុ បានពោលទៅកាន់ភិក្ខុជាសំឡាញ់ថា៖ «ម្នាលសំឡាញ់! សមណៈសិទ្ធត្ថនេះអស់មានសីលធម៌ទៀតហើយ គ្មានអ្នកណា ម្នាក់អាចទីពឹងបានទៀតទេព្រោះព្រះអង្គបោះបង់មគ្គធម៌ចោលទាំងពាក់កណ្តាលផ្លូវយ៉ាង នេះ។ ឥឡូវនេះព្រះអង្គក្លាយជាមនុស្សអាត្មានិយម គិតតែជាមួយគំនិតឥតបានការលើរូបកាយផ្ទាល់ខ្លួនប៉ុណ្ណោះ។ គ្មានប្រយោជន៍អ្វី ធ្វើឱ្យពួកយើងនៅបម្រើព្រះអង្គទៀតទេ»។ បន្ទាប់ពីបានពិភាក្សាគ្នារួចហើយ ភិក្ខុទាំង៥រូបក៏បបួលគ្នាទៅយកបាត្រ និងស្បង់ចីវររួចធ្វើដំណើរចេញបាត់ទៅ។ ភិក្ខុទាំង៥រូបបានទៅស្នាក់នៅក្នុងព្រៃធំមួយឈ្មោះ ឥសិបតនមិគទាយវ័ន (សព្វថ្ងៃហៅ សារនាថ) ឋិតនៅទៀបក្រុងពារាណសីក្នុងដែន កាសុី (សព្វថ្ងៃហៅ ប៉េណា រ៉េស)។ ព្រះសមណ សិទ្ធត្ថបានដឹងពីអវត្តមាននៃបញ្ចវគ្គិយភិក្ខុទាំង៥រូបនោះដែរ តែព្រះអង្គ នៅខ្សោយព្រះកាយពលនៅឡើយ។ ព្រះអង្គខំប្រឹងកម្សាទឹកចិត្តនិងសាកល្បងការនោសារជាថ្មីម្តងទៀត ដោយឥតមានខ្លាចអស់ព្រះជន្មសង្ខារឡើយ។ ព្រះអង្គទ្រង់ពិចារណាអំពីបុព្វនិមិត្ត និមិត្តនៃការបាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ។ ព្រះពោធិសត្វទ្រង់ពត់ ព្រះភ្នែន នៅក្រោមម្លប់ពោធិព្រឹក្ស ដ៏សមគួរហើយ ទ្រង់អធិដ្ឋានថា៖ «ស្បែក សរសៃ សាច់និងឈាមរបស់អាត្មាអញចូររីងស្ងួតចុះ បើអាត្មាអញមិនបានសម្រេចពន្លឺត្រាស់ដឹងទេ អាត្មាអញនឹងមិនក្រោកចាកពីរតនបល្លង្កនេះឡើយ។» បន្ទាប់មក ព្រះអង្គទ្រង់ចាប់ផ្តើមចំរើន អនាបានុស្សតិ ធ្វើចិត្តឱ្យស្ងប់ចាកនីវរណធម៌ទាំង៥ ដើម្បីសម្រេចឈានជាលំដាប់។ ព្រះអង្គបានសញ្ជឹងគិតឃើញនូវស្ទឹងនៃសង្ខារខន្ធ ឬសញ្ញាខន្ធ ដែលហូរទៅតាមបណ្តោយស្ទឹងនៃរូបខន្ធនិងវិញ្ញាណខន្ធ។[4] ព្រះអង្គទតឃើញ មនុស្សលោកកំពុងជាប់ជំពាក់គ្មានទីបញ្ចប់ នូវសេចក្តីទុក្ខវេទនា ក៏ព្រោះតែការភ័ន្តច្រឡំនៃ សញ្ញាខន្ធរបស់គេ។ តាមសម្មតិសច្ចៈ (ឬសន្មតិសច្ចៈ ឬការពិតតាមការកំណត់របស់មនុស្ស) មនុស្សម្នាក់ៗមានជំនឿថា អ្វីៗដែលមិនទៀងទាត់ថាជារបស់ ទៀងទាត់ អ្វីៗដែលមិនមែនជារបស់ខ្លួន(អនត្តា) ថាជារបស់ខ្លួន(អត្តា) អ្វីៗដែលគ្មានកើត និងគ្មានស្លាប់ថាមានកើតនិងមាន

---

[4] សូមអាន ធីង ផាន់សុផុន, *ព្រះសមណគោតម មហាសាស្ត្រាចារ្យនៃមនុស្សនិងទេវតា*, ១៩៩៥, ទំព័រ ៤៨-៥៤

ស្លាប់ និង អ្វីៗដែលនៅជាប់គ្នាថាជារបស់ដាច់ចេញ ដោយឡែកពីគ្នា។

**៤.ការត្រាស់ដឹងនូវចតុរារិយសច្ច**

តាមរយៈអធិដ្ឋានសមាធិ ព្រះអង្គបានរកឃើញការពិតឥតល្អៀង ដែល ជនមានបញ្ញាចាស់ក្លាចាក់ធ្លុះ (អរិយបុគ្គលប្រកបដោយលោកុត្តរប្បញ្ញា) ទូទៅអាចពាល់ត្រូវ (យល់ដឹងនិងពិសោធន៍បាន)។ ការពិតពិតប្រាកដ ដែលទាក់ទងនឹងទស្សនៈស្តីពីជីវិតនិងការរស់នៅ នេះមាន ៤ចំណុចសំខាន់គឺ៖ ១.ទុក្ខ ២.សមុទយ ៣.និរោធ ៤.មគ្គ ។ ទុក្ខ ជាការលំបាកនៃនាមរូបពោលគឺសេចក្តីលំបាកកាយមិនសប្បាយចិត្ត។ សមុទយ ជាមូលហេតុនាំឱ្យមានការលំបាក ពោលគឺមកពីអវិជ្ជានិងតណ្ហាជាដើម។ និរោធ (ឬនិព្វាន) ជាការចេញផុតស្រឡះពីទុក្ខព្រោះការអស់ទៅនៃ វានៈ ដែលជាគ្រឿងចាក់ស្រេះទាក់ទាក់រួបរឹតនៃតណ្ហា នៅក្នុងសន្តានចិត្តសត្វ។ មគ្គគឺវិធីរស់នៅឱ្យបានល្អត្រឹមត្រូវ។

**៥.ទស្សនៈស្តីពីជីវិតរបស់ព្រះពុទ្ធគោតម**

កំណើតសត្វលោកមានច្រើនប្រភេទ ក្នុងនោះមាន អណ្ឌជៈ, ជលាពុជៈ, សំសេទជៈ, ឱបបាតិកៈ ជាដើម។ ១.អណ្ឌជៈ សំដៅយកសត្វទាំងឡាយណា ដែលមកអាស្រ័យក្នុងស៊ុតហើយបោះទំលាយសំបកស៊ុតចេញមក ដូចជា សត្វចាបលលក មាន់ ទា ជាដើម។ ២.ជលាពុជៈ សំដៅយកសត្វទាំងឡាយណា ដែលសម្រាលចេញពីផ្ទៃមេ ឬ ផ្ទៃម្តាយដូចជា សត្វមនុស្ស គោ ក្របី ឆ្កែ ឆ្មា ដំរី សេះ ជាដើម។ ៣. សំសេទជៈ សំដៅយកសត្វទាំងឡាយណា ដែលកើតចេញពីត្រីស្អុយ សាកសព ឬក្នុង វត្ថុជូរផ្អូម ដូចជាៈ សត្វដង្កូវជាដើម។ ៤.ឱបបាតិកៈ សំដៅយកសត្វទាំងឡាយណាដែលកើតឡើងឯងៗ ដូចជាទេវតា នរក ប្រេតជាដើម។

ព្រះសមណគោតម បង្ហាញថា ការកើតមានជីវិត(ជាតិ)ទាំងឡាយ បណ្តាលមកពីធាតុអវិជ្ជា។ ជីវិតគឺសង្ខតធាតុនៃទឹកដីភ្លើងខ្យល់តាមច្បាប់ធម្មជាតិ។ ជីវិតពុំមែន កើតមានដោយសារព្រះអាទិទេពអង្គណាមួយ ជាអ្នកជប់បង្កើតឡើយ។ ជីវិត និង អ្វីៗទាំងអស់តែងប្រែប្រួល មិនស្ថិតស្ថេរឡើយ, វាតែងរងសម្ពាធជាទុក្ខ (លំបាក) វាមិនមែនជាកម្មសិទ្ធិរបស់ខ្លួនវាឡើយ ។ ព្រះអង្គបញ្ជាក់ថា៖ «នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា»។ ជីវិតកើតនិងស្លាប់ក្នុងវាលវដ្តសង្សារនៃចក្រវាឡ គឺត្រូវស្ថិតនៅក្រោម អំណាចនៃកម្មផល តាម ទ្រឹស្តីបដិច្ចសមុប្បាទ។ បដិច្ចសមុប្បាទ គឺជា ធម៌ឬសភាវៈដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងតៗគ្នាមាន១២កងជាប់គ្នាគឺ៖ ១.អវិជ្ជាជាបច្ច័យឲ្យកើតសង្ខារ, ២.សង្ខារជាបច្ច័យឲ្យកើតវិញ្ញាណ, ៣.វិញ្ញាណជាបច្ច័យឲ្យកើតនាមរូប ៤.នាមរូបជាបច្ច័យឲ្យកើតអាយតនៈ ៥.អាយតនៈជាបច្ច័យឲ្យកើតផស្សៈ ៦.ផស្សៈជាបច្ច័យឲ្យកើតវេទនា, ៧.វេទនាជាបច្ច័យឲ្យកើតតណ្ហា ៨.តណ្ហា ជាបច្ច័យឲ្យកើតឧបាទាន,

៩.ឧបាទានជាបច្ច័យឲ្យកើតភព ១០.ភពជាបច្ច័យឲ្យកើតជាតិ, ១១.ជាតិជាបច្ច័យឲ្យកើតមាន ១២.ជរា (ព្យាធិ សោក ទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត កន្ទក់កន្ទេញ សោកសង្រេង) និង មរណៈ គឺបែកធ្លាយទៅជាទឹកដីភ្លើងខ្យល់ ដែលជាធាតុអវិជ្ជាវិញ។ ការវិលវល់កើតស្លាប់ (ជាតិ មរណៈ) ឬ ស្លាប់កើត (ចុតិ បដិសន្ធិ) ក្នុងវាលវដ្ដសង្សារ គឺបណ្ដាលមកពីធាតុអវិជ្ជាជាបច្ច័យ។

ព្រះអង្គបង្ហាញថា ជីវិតគឺជាគំនរនៃមហាភូតរូប៤(ចតុភូត) គឺទឹកដីភ្លើងខ្យល់។ រូបធាតុទាំងនេះវាមិនដឹងអីឡើយ គឺវាជាធាតុអវិជ្ជា(ទឹកដីភ្លើងខ្យល់)។ ធាតុអវិជ្ជាទាំងនេះបង្កទៅជាខន្ធ៥ (បញ្ចខន្ធ) គឺរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ដែលជារួមហៅថា នាមរូប។ រូបក្ខន្ធ ជារចនាសម្ពន្ធនៃកាយ ឬតួខ្លួន ឬរាងកាយ ហៅខ្លីថា រូប, ចំណែកវេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ សំដៅលើចិត្ត ចេតសិក ហៅខ្លីថា នាម។ រូបនាម ឬនាមរូប ជាគោលការណ៍ចម្បងនៃជីវិត ដែលមិនអាចផ្ដាច់ចេញពីគ្នាបានឡើយ។

ព្រះពុទ្ធជ្រាបច្បាស់នូវ ចិត្ត ចេតសិក រូប និព្វាន។ ១.រូបក្ខន្ធ អង្គធម៌ បានដល់ រូប២៨។ ២.វេទនាខន្ធ អង្គធម៌ បានដល់ វេទនាចេតសិក។ ៣.សញ្ញាខន្ធ អង្គធម៌ បានដល់ សញ្ញាចេតសិក។ ៤.សង្ខារក្ខន្ធ អង្គធម៌ បានដល់ ចេតសិក៥០។ ៥.វិញ្ញាណក្ខន្ធ អង្គធម៌ បានដល់ ចិត្ត ៨៩ ឬ ១២១។

អាចនិយាយបានថា ជីវិត គឺការផ្សំរវាងចិត្ត និងកាយ ឬទំនាក់ទំនងនៃនាម និង រូប។ ជីវិតតែងរងការលំបាក(ទុក្ខ) មិនស្ថិតស្ថេរតាំងជានិច្ចទេ វាតែងប្រែប្រួល(អនិច្ចំ)រលត់រលាយ (មរណៈ ឬចុតិ) ទៅវិញជាធម្មតា, វាមិនធ្វើតាមបង្គាប់ ឬការចង់បានរបស់យើងទេ ព្រោះវាមិនមែនជាកម្មសិទ្ធិពិតប្រាកដរបស់ខ្លួនបុគ្គល(អនត្តា) នោះឡើយ អ្វីៗសុទ្ធតែប្រែប្រួល(អនិច្ចំ) ហើយមានតែការប្រែប្រួល (អនិច្ចំ) នេះទេ ដែល មិនដែលប្រែប្រួល។

## ៦.ទស្សនៈស្ដីពីការរស់នៅរបស់ព្រះពុទ្ធ

ការរស់នៅ គឺជាអត្ថិភាពនៃជីវិត ឬជាដំណើរប្រព្រឹត្តិទៅនៃជីវិត(ឬអត្ថិភាពនាមរូប, ដំណើរប្រព្រឹត្តទៅនៃចិត្តកាយ)។ ព្រះពុទ្ធយល់ឃើញថាជីវិតជាដំណើរទំនាក់ទំនងនៃនាម-រូប។ ការរស់នៅតែងជួបនូវសេចក្ដីលំបាក(ទុក្ខ) ជួបនូវសេចក្ដីស្រណុកស្រួល (សុខ) និងការមិនលំបាក មិនស្រណុកស្រួល(អទុក្ខមសុខ)។ តាមពិតគ្មាននរណាម្នាក់ចង់ជួបសេចក្ដីទុក្ខវេទនាឡើយ ប៉ុន្ដែ ដោយសារតែតណ្ហា ចាក់ស្រេះក្នុងសន្ដានចិត្ត(ព្រោះមានពូជអកុសលចិត្តមាន១២គឺៈ លោភមូលចិត្ត៨, ទោសមូលចិត្ត២, មោហមូលចិត្ត២) ដែលកើតពីអកុសលចេតសិក ដែលជាសភាវគតិពីកំណើត និងលូតលាស់បណ្ដាលឱ្យមនុស្សជួបនូវទុក្ខទោសឥតស្រាកស្រាន្ត។ តើត្រូវ

រស់របៀបណាដើម្បីឱ្យជីវិតទទួលបាននូវសេចក្តីសុខចម្រើនចាកទុក្ខសោក។

ដើម្បីរស់នៅប្រកបដោយសុខ ចាកទុក្ខ ព្រះពុទ្ធបានបង្ហាញគោលធម៌ (ដែលជាក្បួន, វិធីសាស្ត្រ, របៀប, មធ្យោបាយ) ជាច្រើន។ នៅឱកាសនេះ សូមលើកយកគោលធម៌ខ្លះមកបង្ហាញជូន ដូចជា៖ អដ្ឋង្គិកមគ្គ (ដែលផ្តោតលើបញ្ញា, សីល, សមាធិ), មង្គលសូត្រ, បរាភវសូត្រ, ព្រហ្មវិហារធម៌, ទសពិធរាជធម៌ ជាដើម។

**៦.១.អដ្ឋង្គិកមគ្គ(បញ្ញា, សីល , សមាធិ)៖** ផ្លូវដែលដឹកនាំជីវិតរបស់យើងឱ្យរស់នៅប្រកបដោយក្តីសុខចម្រើន។ មាគ៌ាធម៌នេះ គឺត្រូវប្រតិបត្តិដោយខ្លួនឯង (អត្តា ហិ អត្តនោ នាថោ)។ អដ្ឋង្គិកមគ្គ(បញ្ញា, សីល, សមាធិ) ជាក្បួនសម្រាប់រស់នៅមួយមាន៨ចំណុចសំខាន់ដែលស្ថិតនៅក្នុងតួ បញ្ញា សីល និង សមាធិ។

ក.តួបញ្ញាមាន២គឺ៖ ១. សម្មាទិដ្ឋិ
២. សម្មាសង្កប្បៈ

ខ.តួសីលមាន៣គឺ៖ ៣.សម្មាវាចា
៤.សម្មាកម្មន្តៈ
៥.សម្មាអាជីវៈ

គ.តួសម្មាធិមាន៣គឺ៖ ៦.សម្មាវាយាម
៧.សម្មាសតិ
៨.សម្មាសមាធិ

ក្នុងការប្រតិបត្តិសីល សមាធិ បញ្ញា គឺប្រៀបដូចជាមុំជើងចង្ក្រាន ដែលខ្វះមួយណាមិនបានឡើយ។ **១.សម្មាទិដ្ឋិ** (ការមានទស្សនៈត្រូវបានដល់ការស្គាល់ច្បាស់នូវអរិយសច្ច:៤)។ **២.សម្មាសង្កប្បៈ** (ការគិតត្រូវ បានដល់ការរិះរកផ្លូវចេញចាកទុក្ខ និងត្រិះរិះពីនាមរូបំ អនិច្ចំ ទុក្ខំ អនត្តា ជាដើម)។ **៣.សម្មាវាចា** (ការនិយាយត្រូវបានដល់ និយាយផ្តល់ប្រយោជន៍ដល់អ្នកស្តាប់ ជៀសវាងសំដីកុហក់បោកប្រាស់ ញុះញង់ បំបែកបំបាក់ ចាក់ដោត ដៀមដាម រឡេះរឡោះឥតប្រយោជន៍)។ **៤.សម្មាកម្មន្តៈ** (ការធ្វើប្រព្រឹត្តអំពើសកម្មភាពត្រឹមត្រូវ បានដល់ ការមិនសម្លាប់ជីវិត មិនលួចប្លន់ មិនផិតក្បត់ មិនសេពគ្រឿងញៀនស្រវឹង និងត្រូវដេកដើរឈរអង្គុយឱ្យបានសមស្រប)។ **៥.សម្មាអាជីវៈ**(ការចិញ្ចឹមជីវិតត្រូវបានដល់ មិនលក់គ្រឿងអាវុធ គ្រឿងញៀនស្រា មិនបើកបនល្បែងស៊ីសង បនពេស្យា និងត្រូវចេះប្រមាណក្នុងការបរិភោគ សេពមេថុន និងធ្វើការងារមិនច្របូកច្របល់)។ **៦.សម្មាវាយាមៈ** (ការព្យាយាមត្រឹមត្រូវ បានដល់ការព្យាយាមលះបង់អំពើអកុសល សន្សំអំពើល្អ រក្សាអំពើល្អឱ្យស្ថិតនៅគង់វង្ស និងសាងគុណធម៌បន្ថែម)។ **៧.សម្មាសតិ** (ការមានសតិរលឹកត្រឹមត្រូវ បានដល់មានសតិសម្បជញ្ញភ្ញាក់រលឹកនូវការដែលកំពុងធ្វើ កុំភ្ញាត់ឡប់សតិមិនដឹងធ្វើអ្វី ហើយជារឿយៗសតិតាមទាន់នូវការពិនិត្យមើលអកុសលចេតសិក ជាដើម)។ **៨.សម្មាសមាធិ** (ការធ្វើចិត្ត ឬការតាំងចិត្តត្រឹមត្រូវ បានដល់ការទម្លាប់ចិត្តឱ្យរឹងមាំក្នុងការគិតពិចារណា ដើម្បីសម្រេចគោល

បំណងណាមួយ ដូចជាការយល់ដឹងអំពីខ្លួនឯង អំពីជីវិត និងយល់ដឹងអំពីអ្នកដទៃ។

តួយ៉ាងនៃវិធីសម្មាសមាធិ គឺៈវិបស្សនា និង សមថ។ **វិបស្សនា** ការពិចារណាឃើញច្បាស់តាមពិត; ប្រាជ្ញាពិចារណាឃើញច្បាស់នូវដំណើរសង្ខារធម៌តាមការណ៍ពិត។ វិបស្សនាញាណ ឬ វិបស្សនាបញ្ញា ញាណឬប្រាជ្ញាដែលពិចារណាឃើញនូវដំណើរសង្ខារធម៌តាមការណ៍ពិត។ វិបស្សនាធុរៈ (កិច្ចធ្វើសមាធិត្រិះរិះពិចារណាដើម្បីចម្រើនបញ្ញា) ជាគូគ្នានឹង គន្ថធុរៈ ( កិច្ចខាងការសិក្សារៀនទន្ទេញ )។ ការធ្វើសមាធិតាមបែបវិបស្សនា គឺជា "ការធ្វើការវិភាគ" ដោយយើងប្រើប្រាស់នូវហេតុផលដើម្បីធ្វើការអភិវឌ្ឍន៍ខ្លួនយើងមួយជំហានម្តងៗឆ្ពោះទៅកាន់សភាពជាវិជ្ជមាននៃចិត្តដូចជាសេចក្តីស្រលាញ់ ឬក៏យើងប្រើប្រាស់ហេតុផលដើម្បីវិភាគនូវស្ថានការណ៍ណាមួយ ឬក៏យើងគ្រាន់តែបង្កើតនូវរូបភាពអ្វីមួយនៅក្នុងចិត្តប្រកបដោយផលវិជ្ជមាននានាដូចជាទ្រង់ទ្រាយនៃរូបព្រះពុទ្ធអង្គជាដើមហើយព្យាយាមធ្វើការវិភាគត្រិះរិះពិចារណានូវរូបនោះឱ្យរិតតែច្បាស់ឡើង។ ចំណែក **សមថ** ជាការធ្វើសមាធិដោយតម្កល់ចិត្តឱ្យនឹងនរនិងការចម្រើនសតិ ដោយផ្តើមពីអាណាបាសតិ ជាដើម។ នៅក្នុងសមថ យើងប្រើប្រាស់នូវសតិរលឹកដឹងដោយការយកចិត្តទុកដាក់និងប្រើប្រាស់ការផ្តោតអារម្មណ៍ ដើម្បីធ្វើការរក្សានូវសភាពជាវិជ្ជមាននៃចិត្តដែលយើងបានបង្កើតឡើងហើយឱ្យនៅជាមួយយើងរិតតែយូររឹតតែប្រសើរ ឬក៏យើងអនុវត្តប្រើប្រាស់នូវវិធីសាស្រ្តទាំងនេះដើម្បីធ្វើការរក្សានូវការផ្តោតអារម្មណ៍ដែលមិនមានការរំខានទៅលើរូបភាពនៃចិត្តដែលយើងបានបង្កើតឡើង។ យើងអាចធ្វើការឆ្លាស់គ្នារវាងប្រភេទនៃការធ្វើសមាធិទាំងពីរ (វិបស្សនា និងសមថ) បាន នៅពេលណាយើងបានបង្កើនសមត្ថភាពខ្ពស់បានហើយ។ ពេលនោះយើងអាចធ្វើការត្រិះរិះវិភាគនូវសភាពជាវិជ្ជមាននៃចិត្តដែលយើងប្រាថ្នាចង់បាន។ យើងធ្វើឱ្យវាមានលំនឹងហើយនៅពេលណាដែលការផ្តោតអារម្មណ៍របស់យើងនៅខណៈនេះចុះខ្សោយឬបាត់បង់នោះយើងត្រូវធ្វើវាឡើងវិញសារជាថ្មីដើម្បីបង្កើតនូវការត្រិះរិះពិចារណាបន្ថែមទៀត។

ការចំណាយពេលវេលាហ្វឹកហាត់ចិត្តរបស់យើងឱ្យប្រសើរតាមរយៈធ្វើសមាធិ បានផ្តល់អត្ថប្រយោជន៍ ដល់ការរស់នៅប្រចាំថ្ងៃរបស់មនុស្សដោយនាំឱ្យមានសេចក្តីសុខសប្បាយរីករាយចិត្ត តាមរយៈការធ្វើឱ្យខ្សោយចុះនូវអកុសលចេតសិកទាំង១៤ ហើយចម្រើនអញ្ញសមានាចេតសិកទាំង១៣ និង សោភណចេតសិកទាំង២៥។

**ចេតសិក** ជាសភាវៈដែលប្រកបផ្សំនឹងចិត្ត កើតរលត់ព្រមជាមួយនឹងចិត្ត ដែលរួមមាន៥២ គឺ អកុសលចេតសិក១៤, អញ្ញសមានាចេតសិក ១៣, សោភណចេតសិក២៥។

***អកុសលចេតសិក ១៤ គឺៈ*** ១.មោហៈ ជាសភាវធម៌ដែលវង្វេងក្នុងអារម្មណ៍ មិនដឹងសច្ចធម៌ បុណ្យ និងបាបៗ ២.អហិរិកៈ ជាសភាវធម៌ដែលមិនខ្មាសខ្ពើមបាបៗ ៣.អនោត្តប្បៈ ជាសភាវធម៌ដែលមិនក្រែងខ្លាចបាប ព្រោះមិនឃើញទោសរបស់បាបៗ ៤-ឧទ្ធច្ចៈ ជាសភាវធម៌ដែលកញ្ជ្រោលចិត្ត មិនស្ងប់ក្នុងអារម្មណ៍ រាយមាយ រវើរវាយ ។ ៥.លោភៈ ជាសភាវធម៌ដែលជាប់ជំពាក់អារម្មណ៍ ពេញចិត្ត ប្រាថ្នា ចង់បានៗ ៦.ទិដ្ឋិៈ ជាសភាវធម៌ដែលយល់ឃើញខុសក្នុងសច្ចធម៌ៗ ៧.មានះ ជាសភាវធម៌ដែលលើកតម្កើងខ្លួនប្រកាន់មាំក្នុងមិច្ឆាទិដ្ឋិៗ ៨.ទោសៈ ជាសភាវធម៌ដែលប្រទូស្តអារម្មណ៍ មិនពេញចិត្ត ខឹង ស្អប់ៗ ៩.ឥស្សាៈ ជាសភាវធម៌ដែលកើតសេចក្តីច្រណែន ។ ១០.មច្ឆរិយៈ ជាសភាវធម៌ដែលកើតសេចក្តីកំណាញ់ ។ ១១.កុក្កុច្ចៈ ជាសភាវធម៌ដែលក្តៅក្រហាយចិត្ត សោកសៅសោកស្តាយៗ ១២.ថីនៈ ជាសភាវធម៌ដែលរួញរាអស់កម្លាំងចិត្ត ខ្ជិលច្រអូស លះបង់សេចក្តីព្យាយាមៗ ១៣.មិទ្ធៈ ជាសភាវធម៌ដែលងោកងុយពថយៗ ១៤.វិចិកិច្ឆា ជាសភាវធម៌ដែលមានការសង្ស័យ ញាប់ញ័រ ស្ទាក់ស្ទើរ មិនមានទំនុកជំនឿៗ

***អញ្ញសមានាចេតសិក១៣ គឺ ៖*** ១.ផស្សោ ២.វេទនា ៣.សញ្ញា ៤.ចេតនា ៥.ឯកគ្គតា ៦.ជីវិតិន្ទ្រិយ៍ ៧.មនសិការ ៨.វិតក្កៈ ៩.វិចារៈ ១០.អធិមោក្ខៈ ១១. វិរិយៈ ១២.បីតិ ១៣. ឆន្ទៈ ។

***សោភណចេតសិក២៥ គឺៈ*** ១.សទ្ធា ជាធម្មជាតិជឿកម្ម និងផលនៃកម្មៗ ២.សតិ ជាធម្មជាតិធ្វើចិត្តឲ្យរឮកៗ ៣.ហិរិ ធម្មជាតិខ្មាស ឬខ្ពើមអំពើទុច្ចរិតៗ ៤.ឱត្តប្បៈ ជាធម្មជាតិស្លុតខ្លាចអំពើទុច្ចរិតៗ ៥.អលោភោ សភាពមិនធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍ៗ ៦.អទោសោ សភាពមិនប្រទុស្តៗ ៧.តត្រមជ្ឈត្តតា ជាធម្មជាតិព្រងើយកន្តើយក្នុងសត្វ និងសង្ខារៗ ៨.កាយបស្សទ្ធិ ជាសេចក្តីរំងាប់កាយៗ ៩.ចិត្តបស្សទ្ធិ ជាសេចក្តីរំងាប់ចិត្តៗ ១០.កាយលហុតា ជាភាវៈនៃកាយដ៏ស្រាលៗ ១១.ចិត្តលហុតា ភាវៈនៃចិត្តដ៏ស្រាលៗ ១២.កាយមុទុតា ភាវៈនៃកាយដ៏ទន់ៗ ១៣.ចិត្តមុទុតា ជាភាវៈនៃចិត្តដ៏ទន់ៗ ១៤.កាយកម្មញ្ញតា ជាភាវៈនៃកាយដ៏គួរដល់ការងារៗ ១៥.ចិត្តកម្មញ្ញតា ភាវៈនៃចិត្តដ៏គួរដល់ការងារៗ ១៦.កាយបាគុញ្ញតា ភាវៈនៃកាយដ៏ស្ទាត់ជំនាញៗ ១៧.ចិត្តបាគុញ្ញតា ជាភាវៈនៃចិត្តដ៏ស្ទាត់ជំនាញៗ ១៨.កាយុជុកតា ជាភាវៈនៃកាយដ៏ត្រង់ៗ ១៩.ចិត្តុជុកតា ភាវៈនៃចិត្តដ៏ត្រង់ៗ ២០.សម្មាវាចា ចេតនាជាហេតុពោលល្អវៀរចាកវចីទុច្ចរិតៗ ២១.សម្មាកម្មន្តោ ការងារល្អវៀរចាកកាយទុច្ចរិតៗ ២២.សម្មាអាជីវោ ចិញ្ចឹមជីវិតល្អ វៀរចាកជំនួញ៥ប្រការៗ ២៣.ករុណា សេចក្តីអាណិតប្រុងនឹងដោះទុក្ខសត្វឲ្យរួចចាកទុក្ខៗ ២៤.មុទិតា សេចក្តីបន្ទន់ចិត្តទៅក្នុងសម្បត្តិនៃបុគ្គលដទៃៗ ២៥.បញ្ញា ជាធំជាងសហជាតិធម៌ទាំងពួងៗ បញ្ញាអាចកើតឡើងដោយហេតុ ៣

ប្រការៈ ១.សុតមយបញ្ញា ប្រាជ្ញាដែលកើតអំពីការស្តាប់; ការសិក្សារៀនសូត្រ។ ២.ចិន្តាមយបញ្ញា, បញ្ញាកើតពីការគិតពិចារណារកហេតុផល។ ៣. ភាវនាមយបញ្ញា បញ្ញាកើតពីការហ្វឹកហ្វឺនអប់រំ បដិបត្តិអនុវត្តក្នុងជីវភាពប្រចាំថ្ងៃនិងកើតពីការធ្វើសមាធិ។

មនុស្សគ្រប់ភេទ គ្រប់វ័យអាចប្រតិបត្តិអដ្ឋង្គិកមគ្គ ឬ សីល សមាធិ បញ្ញា បានគ្រប់ពេលានិងពេញមួយជីវិត ដោយខ្លួនឯង(អត្តាហិ អត្តនោនាថោ) មិនមានអ្នកណាដទៃ ប្រតិបត្តិជំនួសខ្លួនជាបុគ្គលឡើយ។

**៦.២.មង្គលសូត្រ៖** ជាពុទ្ធភាសិត សម្រាប់ទេវតានិងមនុស្សទាំងឡាយ ដែលប្រាថ្នារស់នៅក្នុងមង្គលដ៏ឧត្តម មានសិរីសួស្តី។ ព្រះពុទ្ធសម្តែងនូវគាថា ដែលមាន៣៨ប្រការៈ១.កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ (អសេវនា ចពាលានំ)។ ២.កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ (បណ្ឌិតានញ្ច សេវនា)។ ៣.កិរិយាបូជាដល់បុគ្គលដែលគួរបូជា (បូជា ចបូជនីយានំ)។ ៤.កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ(បដិរូបទេសវាសោច)។ ៥.ភាវៈនៃអ្នកបានធ្វើបុណ្យទុកហើយក្នុងកាលមុន (បុព្វេកតបុញ្ញតា)។ ៦.កិរិយាតម្កល់ខ្លួនទុកដោយប្រពៃ (អត្តសម្មាបណិធិ ច)។ ៧.ភាវៈជាបុគ្គលបានស្តាប់បានរៀនសូត្រចេះដឹងច្រើន (ពាហុសច្ចៈ)។ ៨.សេចក្តីឈ្លៀវឆ្លាតប៉ិនប្រសប់ក្នុងសិល្បៈទាំងពួង (សិប្បៈ)។ ៩.វិន័យដែលបុគ្គលបានសិក្សាហើយដោយប្រពៃ (វិនយោ ចសុសិក្ខិតោ)។ ១០.វាចាដែលបុគ្គលពោលដោយប្រពៃ (សុភាសិតា ច យា វាចា)។ ១១.កិរិយាបម្រើ ឬ ទំនុកបម្រុងមាតា (មាតាបិតុ ឧបដ្ឋានំ)។ ១២.កិរិយាបម្រើ ឬ ទំនុកបម្រុងបិតា (មាតាបិតុ ឧបដ្ឋានំ)។ ១៣.កិរិយាសង្គ្រោះបុត្រ និងភរិយា (បុត្តទារស្សសង្គហោ)។ ១៤.ការងារទាំងឡាយដែលមិនច្របូកច្របល់ (អនាកុលា ចកម្មន្តា)។ ១៥.កិរិយាបរិច្ចាគទាន (ទានំ)។ ១៦.កិរិយាប្រព្រឹត្តធម៌ដ៏ប្រសើរ (ធម្មចរិយា)។ ១៧.កិរិយាសង្គ្រោះញាតិទាំងឡាយ (ញាតកានញ្ច សង្គហោ)។ ១៨.កិរិយាប្រកបការងារទាំងឡាយដែលមិនមានទោស(អនវជ្ជានិ កម្មានិ)។ ១៩.កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប (អារតី វិរតីបាបា)។ ២០.សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង (មជ្ជបានា ច សញ្ញមោ)។ ២១.ការមិនប្រមាថក្នុងធម៌ទាំងឡាយ (អប្បមាទោ ចធម្មេសុ)។ ២២.កិរិយាគោរពចំពោះបុគ្គលដែលគួរគោរព (គារវោ ច)។
២៣.កិរិយាប្រព្រឹត្តបន្ទាបខ្លួន (និវាតោ ច)។ ២៤.សេចក្តីសណ្តោសត្រេកអរចំពោះរបស់ដែលមាន (សន្តុដ្ឋី ច)។ ២៥.ភាពជាអ្នកដឹងឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន (កតញ្ញុតា) ២៦.កិរិយាស្តាប់នូវធម៌តាមកាល (កាលេន ធម្មស្សវនំ)។ ២៧.សេចក្តីអត់ធ្មត់(ខន្តិ ច)។ ២៨.ភាវៈនៃបុគ្គលដែលទូន្មានប្រៀនប្រដៅបានដោយងាយ (សោវចស្សតា)។ ២៩.កិរិយាបានឃើញ

បានជួបនូវសាមណៈទាំងឡាយដែលមានឥន្ទ្រិយ៍ស្ងប់រំងាប់ហើយ(សមណានញ្ច ទស្សនំ)។ ៣០.កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល(កាលេនធម្មសាកច្ឆា)។ ៣១.សេចក្តីព្យាយាមដុតនូវបាបធម៌ (តបោ ច)។ ៣២.កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ (ព្រហ្មចរិយញ្ច )។ ៣៣.កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ( បរិយសច្ចានទស្សនំ )។ ៣៤.កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយបញ្ញាដ៏ខ្ពង់ខ្ពស់ ( និព្វានសច្ឆិរិយាច )។ ៣៥.ចិត្តនៃបុគ្គលដែលមិនញាប់ញ័រដោយលោកធម៌ (ផុដ្ឋស្ស លោកធម្មេហិ ចិត្តំយស្ស នកម្បតិ)។ ៣៦.ចិត្តនៃបុគ្គលមិនសោយសោកចំពោះអារម្មណ៍(អសោកំ)។ ៣៧.ចិត្តដ៏បរិសុទ្ធស្អាតចាកកិលេស(វិរជំ )។ ៣៨.ចិត្តក្សេមក្សាន្ត(ខេមំ)។[5]

**៦.៣.បរាភវសូត្រៈ** សេចក្តីបង្រៀនរបស់ព្រះពុទ្ធឲ្យមនុស្សស្គាល់មូលហេតុ ១២ ប្រការ ដែលជាប្រធាននាំមកនូវក្តីវិនាស ដែលមនុស្សត្រូវវៀរចាក ចៀសវាង ដើម្បីរស់នៅក្នុងសេចក្តីសុខស្ងប់ និង ចម្រុងចម្រើន ។ ហេតុដែលនាំឱ្យវិនាស១២ប្រការមាន៖ ១.ទ្រុស្តធម៌ស្អប់ធម៌។ ២.សេពគប់អសប្បុរស(មនុស្សពាល) ហើយស្អប់សប្បុរស(បណ្ឌិត)។ ៣.ដេកច្រើន និយាយច្រើន ឥតព្រួយ ឥតគិតប្រឹងប្រែង ខ្ជិលប្រអូស មិនខ្នះខ្នែង ខឹងច្រើនសម្តែងឲ្យគេឃើញ។ ៤.ទ្រព្យធនធាន ហើយមិនបានចិញ្ចឹមរក្សា មាតាបិតាដែលចាស់ជរា។ ៥.កុហក មុសា បញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូម ឬអ្នកដទៃ។ ៦.សម្បូរទ្រព្យធនធាន មាសប្រាក់ គ្រឿងអាហារ ឆ្ងាញ់ពិសាមិនចែករំលែកដល់អ្នកដទៃ។ ៧.ប្រកាន់ជាតិទ្រព្យត្រកូល អាងខ្លួនមានមិនរាប់សាច់ញាតិសន្តានមើលងាយញាតិខ្លួន ។ ៨.ប្រព្រឹត្ត អបាយមុខបីប្រការគឺ ស្រី ស្រា ល្បែងភ្នាល់។ ៩.មិនត្រេកអរនឹងប្រពន្ធខ្លួនបែរជាទៅត្រេកត្រអាលនឹងស្រីពេស្យា ទ្រុស្តនឹងប្រពន្ធកូនគេ។ ១០.បុរសចាស់ពេក យកស្រីក្មេងមកធ្វើករិយា។ ១១.បុរសនិងស្ត្រីចូលចិត្តលេងខ្នះខ្នាយ ដូចគ្នា។ ១២.ត្រកូលជាក្សត្រដែលក្សត់សម្បត្តិហើយប្រាថ្នាធំចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ។ ចំណុចទាំង១២ប្រការដែលរៀបរាប់ខាងលើនេះសុទ្ធតែជាប្រធាននាំដល់សេចក្តីវិនាស ដែលមនុស្សទាំងឡាយគួរចៀសវាង។

**៦.៤.ព្រហ្មវិហារធម៌ៈ** ១.មេត្តា ឬមេត្រី ការរាប់អាន មិនរើសអើង, ២.ករុណា ការអាណិតអាសូរអ្នកដែលជួបការលំបាក, ៣.មុទិតា ការអបអរ រីករាយជានិច្ចចំពោះសេចក្តីសុខ-ចម្រើននៃអ្នកដទៃ, ៤.ឧបេក្ខា ការតាំងចិត្តជាកណ្តាលមិនលំអៀងដោយអគតិ។ ព្រហ្មវិហារធម៌ទាំងបួននេះជាប្រភពនៃសន្តិភាពនិងវឌ្ឍនភាព គ្រប់ពេលវេលានិងគ្រប់ទីកន្លែង។

**៦.៥.ទសបារមី** (**បារមី ១០**) គឺចរិយាដ៏លើសលន់ ឬគុណជាតិដ៏ល្អ ដែលគួរបំពេញមាន ១០

[5] មង្គលសូត្រព្រះត្រៃបិដក សុត្តន្តបិដក ខុទ្ទកនិកាយ ត្រង់ខុទ្ទកបាឋ: ភាគ៥២ ទំព័រទី ១ ដល់ ២០

យ៉ាងគឺ ១.ទាន ការធ្វើអំណោយ; ២.សីល ការរក្សាកាយវាចាឲ្យបរិសុទ្ធប្រពៃ; ៣.នេក្ខម្មៈ ការចេញចាកកាម គឺចេញបួស; ៤.បញ្ញា ការដឹងច្បាស់នូវសេចក្ដីពិត; ៥.វិរិយៈ ព្យាយាម; ៦.ខន្តិ សេចក្ដីអត់ធន់; ៧.សច្ចៈ ការកាន់សំដីពិតមិនវេរុះ; ៨.អធិដ្ឋានៈ ការអធិដ្ឋានឲ្យឃើញជាក់ស្ដែងតាមហេតុពិត; ៩.មេត្តា ការផ្សាយសេចក្ដីរាប់អានចំពោះសព្វសត្វមិនរើសមុខ; ១០-ឧបេក្ខា ដំណើរតាំងចិត្តដើយព្រងើយដោយស្មោះស្មើ។ បារមីទាំង ១០ នេះឯងដែលពោធិសត្វរាល់ព្រះអង្គបំពេញឲ្យបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ។

**៦.៦.ទសពិធរាជធម៌៖** (ច្រើនហៅកាត់ខ្លីត្រឹមតែ ទសពិធ ឬ ទសពិធធម៌ ឬរាជធម៌ ១០ យ៉ាង)ធម៌ ១០ ប្រការសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្តព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រ ប្រជាឲ្យប្រព្រឹត្តផង។ ទសពិធរាជធម៌នោះគឺ៖ ១-ទានៈ ការធ្វើអំណោយ; ២-សីលៈ ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ មួយដងមួយកាល; ៣-បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ; ៤-អាជ្ជវៈ មានសេចក្ដីត្រង់; ៥-មទ្ទវៈ មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា; ៦-តបៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ ឬការប្រព្រឹត្តកាន់វត្តយ៉ាងតឹងដើម្បីធ្វើកាយនិងចិត្តឲ្យស្ងប់។ ៧-អក្កោធនៈ មិនកម្ដៅក្រហាយអ្នកដទៃ; ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ; ៩- ខន្តិ មានសេចក្ដីអត់ធន់; ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់។

**៦.៧.ចក្កធម៌ ៤ យ៉ាង គឺ៖** ១.បដិរូបទេសវាសោ នៅអាស្រ័យក្នុងប្រទេសដ៏សមគួរ (មានយុត្តិធម៌ វិបុលភាព សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយ។ ២.សប្បុរិសូបស្សយោ ចូលទៅសេពគប់នឹងសប្បុរស(សេពគប់បណ្ឌិត មិនសេពគប់ពាល)។ ៣.អត្តសម្មាបណិធិ កិរិយាតម្កល់ខ្លួនឲ្យប្រពៃ។ ៤.បុព្វេកតបុញ្ញតា ភាពនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន[6]។

## ៧.ការរស់នៅរបស់ភិក្ខុ ភិក្ខុនីសង្ឃ (បព្វជិត, ឬអ្នកគ្មានផ្ទះ)

សាវកព្រះពុទ្ធមាន ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា។ អ្នកបួស ជា ភិក្ខុ ភិក្ខុនី គឺជាសមណៈ ដែលជាអ្នកខ្លាចភ័យក្នុងវដ្តសង្សារហើយមានការព្យាយាមដុតបំផ្លាញអំពើអាក្រក់ទាំងពួង ដោយការខំប្រឹងប្រព្រឹត្តធម៌ធ្វើកាយវាចាចិត្តឲ្យស្ងប់ចាកបាប។ ភិក្ខុ ភិក្ខុនី ឬបព្វជិត ត្រូវរស់នៅអស្រ័យចង្ហាន់បិណ្ឌបាត ដែលប្រគេនដោយគ្រហស្ថ ឬ ឧបាសកឧបាសិកា។ មុនពេលឆាន់ នឹង ភិក្ខុភិក្ខុនី ត្រូវពិចារណាលើចំណុច៨សំខាន់ គឺ នឹងឆាន់នេះដើម្បី៖ ១.លេងដូចក្មេងអ្នកស្រុកក៏ទេ, ២.ឲ្យកើតសេចក្ដីស្រវឹងក៏ទេ, ៣.ប្រដាប់រាងកាយឱ្យរឹងមាំដូចអ្នកប្រដាល់ក៏ទេ, ៤.ស្អិតស្អាងរាងកាយឱ្យស្រីក្រមុំក៏ទេ, ៥.ឲ្យតាំងនៅនៃកាយនេះ, ៦.ញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ, ៧.បំបាត់បង់ នូវសេចក្ដី

[6] សូមមើល សុត្តន្តបិដក លេខ ៤២/៧៩

លំបាក, ៨.អនុគ្រោះ ដល់ព្រហ្មចារ្យ[7]។ បព្វជិតត្រូវពិចារណាថា អាត្មាអញ នឹងធាន់គ្រាន់តែកំចាត់បង់ នូវវេទនាចាស់ គឺសេចក្ដីឃ្លានចេញផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយា ប្រព្រឹត្តទៅ (នៃឥរិយាបថទាំង៤ ដេកដើរឈរអង្គុយ)ក្ដី សេចក្ដីមិនមានទោស(មានមិនប្រអូសកាយ មិនប្រអូសចិត្ត ជាដើម)ក្ដី កិរិយានៅសប្បាយក្ដី នឹងមានដល់អាត្មាអញ[8]។ លោកឱ្យពិចារណាថា ការស្លៀកដណ្ដប់ រាងការដើម្បីគ្រាន់តែបិទបាំងកេរ្ដិ៍ខ្មាស់និងការពារអាកាសធាតុ មេរោគសត្វល្អិតប៉ុណ្ណោះ គឺមិនមែនដើម្បីបង្អួតសម្រស់ដូចកូនអ្នកស្រុកឡើយ។ ជាញឹកញយការរើសសំពត់ដែលជារបស់គ្មានម្ចាស់ ឬសំពត់ទាញចេញពីសាកសព (បង្សុកូល) បានក្លាយជាប្រពៃណីមួយសម្រាប់អរិយបុគ្គដែលជាអ្នកបួសជាបព្វជិតទៅហើយ។

អរិយសង្ឃ(អរិយបុគ្គលជាអ្នកបួស) ជាមនុស្សមិនជាប់ជំពាក់ រំភើបត្រេកអរ ភ្ញាក់ផ្អើលភ័យព្រួយទៅនឹងលោកធម៌ទាំង៨ឡើយ។ លោកធម៌ (ឬលោកធម្មតា) ជាធម៌សម្រាប់លោក គឺអាការ សណ្ដាប់ធ្នាប់ ដែលមិនទៀងធម្មតារបស់សត្វលោក គឺ៖ ១.លាភៈ ការបាន; ២.អលាភៈ ការខានបានឬខាតបង់; ៣.យសៈ ការមានយសស័ក្ដិ; ៤.អយសៈ ការមិនមានយសស័ក្ដិ ឬការថ្លោះធ្លាក់យសស័ក្ដិ; ៥.និន្ទា ការតិះដៀល; ៦.បសំសា ការសរសើរ; ៧.សុខៈ ការបានសុខ; ៨- ទុក្ខៈ ការបានទុក្ខ លំបាក។

ភិក្ខុ មានសិក្ខាបទ ២២៧ ចំណែកភិក្ខុនីត្រូវប្រតិបត្តិសិក្ខាបទ ៣១១។ បព្វជិតដែលប្រពត្តិខុសពុទ្ធប្បញ្ញត្តិត្រូវទទួលអាបត្តិ។ អាបត្តិជាទោសកើតចេញពីការប្រព្រឹត្តបទល្មើសនឹងសិក្ខាបទរបស់ព្រះពុទ្ធ។ អាបត្តិសម្រាប់បព្វជិតមានច្រើនកងគឺ៖ បារាជិក, សង្ឃាទិសេស, ថុល្លច្ច័យ (និស្សគ្គិយបាចិត្តិយ), បាចិត្តតិយ, ទុក្កដ ទុព្ភាសិត។ **អាបត្តិបារាជិក៖** ភិក្ខុត្រូវអាបត្តិបារាជិក[9] ព្រោះប្រព្រឹត្តិដាច់សិក្ខាវិន័យណាមួយក្នុងចំណោមវិន័យទាំង៤ដូចខាងក្រោម៖ ១.មេថុនធម្ម ភិក្ខុសេពមេថុនជាមួយនឹងមនុស្សស្រី សត្វតិរច្ឆានមនុស្សខ្ទើយ, ២.អទិន្នាទាន ភិក្ខុលួចទ្រព្យគេ

[7] តាមគម្ពីរមង្គលត្ថទីបនី អដ្ឋកថា មង្គលសូត្រ បង្ហាញថា ព្រហ្មចារ្យ(ឬបុគ្គលដែលប្រកបដោយព្រហ្មចរិយធម៌) មានចរិយា(ឬការប្រព្រឹត្ត) ១០ប្រការ គឺ៖ ១.ទាន ការឱ្យនូវវត្ថុមានបាយជាដើម, ២.វេយ្យាវច្ច សេចក្ដីខ្វល់ខ្វាយក្នុងការកុសលរបស់អ្នកដទៃជាដើម, ៣.បញ្ចសីល សីលទាំង៥មានវៀរសម្លាប់សត្វជាដើម, ៤.អប្បមញ្ញា គឺព្រហ្មវិហារទាំង៤មានមេត្តាជាដើម, ៥.មេថុនវិរតី ការវៀរមេថុនធម្ម, ៦.សទារសន្តោស សេចក្ដីសន្តោសដោយភរិយារបស់ខ្លួន, ៧.វិរិយ សេចក្ដីព្យាយាមមិនខ្ជិលច្រអូស, ៨.ឧបោសថង្គ អង្គនៃឧបោសថទាំង៨ មានវៀរសម្លាប់សត្វ ជាដើម, ៩.អរិយមគ្គ ផ្លូវមានអង្គ ៨ដ៏ប្រសើរ មានសម្មាទិដ្ឋិជាដើម, ១០.សាសន ពាក្យប្រៀនប្រដៅទាំងអស់របស់ព្រះសាស្ដា។

[8] សូមមើល សុត្តន្តបិដក មជ្ឈិមនិកាយ ភាគ២៥

[9] ឈ្មោះទោសធ្ងន់បំផុតដែលភិក្ខុល្មើសពុទ្ធប្បញ្ញត្តិ។ ភិក្ខុល្មើសនេះ មានឈ្មោះថា អ្នកចាញ់ (ជនបារាជ័យ, បុគ្គលដែលចុះចាញ់) ដែលអស់តម្លៃជាបព្វជិត ហើយត្រូវបណ្ដេញចេញពីបព្វជិតភាវៈត្រូវលាចាកពីភិក្ខុភាវៈ មកជាឃរាវាស(គ្រហស្ថ)មនុស្សបរិស័ទធម្មតាវិញ។

ចាប់ពី៥មាសក:ឡើងទៅ, ៣.មនុស្សវិគ្គហ: ភិក្ខុក្លែងសម្លាប់មនុស្ស, ៤.ឧត្តរិមនុស្សធម្ម[10] ពោលអួតគុណវិសេសរបស់ខ្លួន។ អ្នកប្រព្រឹត្តិអាបត្តិនេះត្រូវតែសឹកចាកភេទពីអ្នកបួស។**អាបត្តិសង្ឃាទិសេស** ជាអាបត្តិស្រាលជាងអាបត្តិបារាជិក។ សង្ឃប្រជុំគ្នាដើម្បីវាយតម្លៃភាពធ្ងន់ស្រាលនៃបទល្មើសដែលភិក្ខុ/ភិក្ខុនីដែលបានធ្វើទាស់នឹងវិន័យណាមួយក្នុងចំណោមទាំងសិក្ខាបទ ១៣ ដើម្បីឲ្យភិក្ខុ/ភិក្ខុនីនោះទទួលកំហុស និង កែប្រែ ទើបសង្ឃអាចទទួលឲ្យចូលក្នុងគណ:វិញ។ ភិក្ខុណាត្រូវអាបត្តិនេះហើយត្រូវនៅដាច់ដោយឡែកពីសង្ឃ គឺមិនត្រូវឲ្យនៅរួមអាវាសវត្តជាមួយសង្ឃទេ លុះតែសង្ឃសម្តែងអាភានកម្មសិនទើបអាចដាច់អាបត្តិសង្ឃាទិសេសនោះ។ ឯការសម្តែងអាភានកម្មនោះ ត្រូវមានភិក្ខុសង្ឃចំនួន២០អង្គ វាខុសពីការធ្វើសង្ឃកម្មផ្សេងៗ។ អាបត្តិសង្ឃាទិសេស១៣ គឺ៖១.សុក្កវិស្សដ្ឋិ ភិក្ខុក្លែងញ៉ាំងទឹកសុក្កៈឲ្យឃ្លាត់ចាក់ទី (ទឹកកាម)។ ២.កាយសំសគ្គ: ភិក្ខុមានតម្រេកចាប់បះកាយស្ត្រី។ ៣.ទុដ្ឋុល្លវាចា តម្រេកនិយាយពាក្យអាក្រក់ចំពោះនិមិត្តស្ត្រី (និយាយអះអាភាស។ ៤.អត្តកាមបារិចរិយា និយាលល្បួងស្ត្រីឲ្យបម្រើកាម។ ៥.សញ្ចរិត្ត: និយាយឲ្យគេបានជាប្តីប្រពន្ធ(ធ្វើមេអណ្តើក )។ ៦.សញ្ញាចិកា ធ្វើកុដិមិនតាមខ្នាត(បណ្តោយ ១២ចំអាមគុណនឹងទទឹង៧ចំអាមនៃព្រះសុគត)។ ៧.មហល្លក ធ្វើកុដិមិនបានឱ្យសង្ឃសំដែងទី ជាមុនចំពោះកុដិធំហួសប្រមាណដែលមានទាយកជាម្ចាស់។ ៨.អមូលក ភិក្ខុក្រោធខឹង និងភិក្ខុឯទៀតហើយក្លែងចោទគេ ដោយអាបត្តិបារាជិកមិនមានមូលហេតុ។ ៩.អញ្ញភាតិយ: ក្រោធខឹង ហើយចោទភិក្ខុផ្សេងដោយអាបត្តិបារាជិក។ ១០.សង្ឃភេទ ភិក្ខុព្យាយាមបំបែកសង្ឃឱ្យបែកគ្នា ភិក្ខុដទៃហាមប្រាមមិនស្តាប់ សង្ឃបានសូត្រសមនុភាសនកម្ម ដើម្បីឱ្យលះបង់ បើមិនលះ។ ១១.ភេទានុវត្តក ភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះ ភិក្ខុដទៃហាម ប្រាមមិនស្តាប់សង្ឃបានសូត្រសមនុភាសនកម្ម ដើម្បីឱ្យបង់ តែមិនលះបង់។ ១២.ទុព្វចជាតិក ភិក្ខុមានជាតិជាអ្នកប្រដៅក្រ ភិក្ខុឯទៀតឃាត់មិនស្តា ប់ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឱ្យលះបង់តែមិនលះបង់។ ១៣.កិលទូសក ភិក្ខុទ្រុស្តត្រកូលគឺភិក្ខុដែលប្រចុបប្រចែងគ្រហស្ថ សង្ឃបានបណ្តេញចេញពីវត្ត ហើយត្រលប់តិះដៀលសង្ឃវិញ សង្ឃបានសូត្រ សមនុភាសនកម្ម ដើម្បីឱ្យលះបង់តែមិនលះបង់។

អាបត្តិទាំង១៣ ខាងលើជាអាបត្តិសង្ឃាទិសេស ពោលគឺបានន័យថាព្រះសង្ឃមិនអនុញ្ញាតឱ្យប៉ះកាយស្ត្រី, មានតម្រេក និយាយលួងលោមស្ត្រីឲ្យបម្រើកាមរបស់ខ្លួន បញ្ចុះ

[10] ការអួតពីឧត្តរិមនុស្សធម្ម គឺជាការអួតថាខ្លួន ជាមនុស្សមានគុណវិសេសលើសលែងជាងមនុស្សធម្មតា ថា ខ្លួនជាព្រះអរិយ:បុគ្គល ដូចជាថាខ្លួនបានសម្រេចនូវ ធម៌សោតាអនាគា ឬថាខ្លួនជាអ្នកស្ងប់រម្ងាប់កិលេស ជាដើម ដើម្បីទទួលបានលាភសក្ការ ពីបរិស័ទ ដែលមានជំនឿពីការអួតនោះ។

បញ្ចូលឲ្យបុរស-ស្ត្រីបានគ្នាជាប្តីប្រពន្ធ ជាដើមឡើយ។ ក្នុងករណីល្មើស ដើម្បីលុបលាងទោសកំហុសនេះបាន ភិក្ខុត្រូវទទួលទណ្ឌកម្មដ៏ធ្ងន់មួយដែលហៅថាការធ្វើ «បរិវាសកម្ម[11]»។ បញ្ញត្តិសង្ឃ(អ្នកបួសជាបុថុជ្ជន)មិនស្រួលបដិបត្តិសិក្ខាបទនេះបានឡើយ ប៉ុន្តែសម្រាប់អរិយសង្ឃ (អ្នកបួសជាអរិយបុគ្គល)អាចប្រតិបត្តិ វិន័យសិក្ខាបទនេះបានយ៉ាងល្អប្រសើរ។

## ៧.ធម៌សម្រាប់រស់នៅរបស់គ្រហស្ថឬអ្នកមានគ្រួសារ

គ្រហស្ថ ឬឧបាសក ឧបាសិកា គឺជាអ្នកមិនលះបង់ផ្ទះសម្បែង គ្រួសារទៅបួសជាបព្វជិតភិក្ខុ ភិក្ខុនី។ ជីវភាពរស់នៅប្រកបដោយការតស៊ូនឹងការលំបាកផ្លូវការចិត្ត ដោយសារតែមោហៈ លោភៈ និង ទោសៈ។

ព្រះពុទ្ធបង្ហាញថា គ្រួសារមានមង្គលសិរីសួស្តី គឺជាគ្រួសារដែលមានសមាជិកប្រកបដោយសមធម៌ ៤ ប្រការគឺៈ ១.សមសទ្ធា ការស្មើគ្នាវាងជំនឿ, ២.សមសីលា ការស្មើគ្នាក្នុងការប្រព្រឹត្តិអំពើកុសល ៣.សមចាគៈ ការស្មើគ្នាក្នុងការលះបង់ចំពោះគ្នា និង៤.សមបញ្ញា ការស្មើគ្នាក្នុងការពង្រឹង ទស្សនៈបញ្ញា។ សមាជិកគ្រួសារត្រូវស្គាល់ចរិត ស្គាល់កិរិយាមារយាទ ស្គាល់ការចូលចិត្ត ស្គាល់សុខ ស្គាល់ទុក្ខទៅវិញទៅមក។ គ្រួសារត្រូវជម្រុញនូវបណ្តុះបណ្តាលបញ្ញាឱ្យយល់ដឹងនិងប្រតិបត្តិដោយខ្លួនឯងនូវ អដ្ឋង្គិកមគ្គ ឬបញ្ញា សីល សមាធិ។

## ៨.សេចក្តីសន្និដ្ឋាន

ការត្រាស់ដឹងរបស់ព្រះពុទ្ធសមណគោតម បានបន្សល់ទុកនូវទ្រឹស្តីស្តីពីជីវិតនិងការរស់នៅដ៏មានសារសំខាន់បំផុតសម្រាប់មនុស្សគ្រប់ជំនាន់ គ្រប់ជាតិសាសន៍ ដែលអាចយកធ្វើជាគតិក្នុងការរស់នៅឱ្យបានសុខចម្រើនប្រកបដោយសន្តិភាព។

ការស្វែងយល់ដឹងអំពីទស្សនៈស្តីពីជីវិតទោះបីជា រឿងហួសនិស្ស័យ ក្នុងការគិត (អចិន្តេយ្យ) សម្រាប់មនុស្សទូទៅ មែន ប៉ុន្តែទស្សនៈស្តីពី ការរស់ ដែលបង្ហាញក្នុងទ្រឹស្តីធម៌ «សីល សមាធិ បញ្ញា ឬអដ្ឋង្គិកមគ្គ» មានលក្ខណៈមិនហួសហេតុសម្រាប់មនុស្សទូទៅឡើយ។ អដ្ឋង្គិកមគ្គ ជាមជ្ឈិមាបដិបទា(ផ្លូវកណ្តាល) ដែលមនុស្សជាតិទូទៅ អាចយល់ដឹង និងអនុវត្តបាន។ អរិយមគ្គនេះ ជាក្បួនឬរបៀបសម្រាប់ រស់នៅ ដ៏ល្អត្រឹមត្រូវមួយ ដែលបស្ចឹមប្រទេសតែងតែឱ្យតម្លៃខ្ពស់។ ពុទ្ធសាសនិកទាំងឡាយគួរសិក្សាឱ្យបានយល់ដឹងច្បាស់តាមគ្រប់មធ្យោបាយ អំពី «សីល សមាធិ បញ្ញា» នេះ ហើយនាំគ្នាប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួន ដើម្បីទទួលបានអានិសង្សទៅតាមឧបនិស្ស័យរៀងៗខ្លួន។

[11] បរិវាសកម្ម គឺជាកិច្ចក្នុងព្រះវិន័យ ដែលតម្រូវឲ្យភិក្ខុ ទទួលកំហុស និង កែប្រែ ទើបសង្ឃអាចទទួលឲ្យចូលក្នុងគណៈវិញ។

**ឯកសារយោង/គន្ថនិទ្ទេស**


១-ធឹង ផាន់សុផុន, *ព្រះសមណគោតម មហាសាស្ត្រាចារ្យនៃមនុស្សនិងទេវតា*, អាម៉េរិក, ១៩៩៥

២-ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

៣-វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដកបាលីនិងសេចក្តីប្រែជាភាសាខ្មែរ*, ភ្នំពេញ, ពស.២៤៩៧

៤-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)